**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ២៣៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១.-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោមនេះ :

ឯកតា លានរៀល

| ជំពូក | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | និយ័តកម្ម | | ឥណទានថ្មី |
|---|---|---|---|---|---|
| | | | កើន | ថយ | |
| | និយ័តកម្មចេញ | | | | |
| | ៩៩- ចំណាយមិនទាន់បែងចែក | | | 1 290 593 | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | 256 000 | - | 256 000 | 0 |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | 333 093 | - | 333 093 | 0 |
| ០៩ | ចំណាយមិនបានគ្រោងទុក | 452 333 | - | 300 000 | 152 333 |
| ១៦ | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 280 000 | - | 280 000 | 0 |
| ២៧ | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 121 500 | - | 121 500 | 0 |
| | និយ័តកម្មចូល | | | | |
| | ១០- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | 1 290 593 | | |
| ៦១ | សេវាខាងក្រៅ | 6 950 | 250 000 | - | 256 950 |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | 0 | 256 000 | - | 256 000 |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | 22 260 | 333 093 | - | 355 353 |
| ៦៣ | ពន្ធនិងអាករ | 113 249 | 50 000 | - | 163 249 |
| ១៦ | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 0 | 280 000 | - | 280 000 |
| ២៧ | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 0 | 121 500 | - | 121 500 |

**មាត្រា២.-** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**